SEARAC

សិទ្ធក្នុងការទទួលបានការព្យាបាលៈ សុខភាពផ្លូវចិត្តប្រចាំរដ្ឋកាលីហ្វញ៉ារបស់ប្រជាជនអាមេរិចដែលកើតនៅអាស៊ីអាគ្នេយ៍(SEARAC)

ព័ត៌មានសម្រាប់អង្គការប្រចាំសហគមន៍ និងអ្នកផ្តល់សេវាកម្ម

ដោយមានការគាំទ្រពីដៃគូប្រចាំសហគមន៍ និងបុគ្គលនៅទូទាំងរដ្ឋកាលីហ្វញ៉ា SEARAC បានបើកដំណើរការអោយមានសេចក្តីរាយការណ៍នូវសិទ្ធទទួលបានការព្យាបាល ដើម្បីគូសបញ្ជាក់នូវគន្លឹះវិបាកផ្សេងៗដែលកើតមានចំពោះប្រជាជនអាមេរិចដែលបានកើតនៅទឹកដីអាស៊ីអាគ្នេយ៍ក្នុងការទទួលបាននូវការថែទាំសុខភាពផ្លូវចិត្តនៅក្នុងរដ្ឋ និងដើម្បីផ្តល់នូវការណែនាំគោលនយោបាយក្នុងការលើកឡើងនូវតម្រូវការរបស់សហគមន៍។ នៅក្នុងឆ្នាំ2019 ពួកយើងប្រមូលបាន250មតិយោបល់ពីសមាជិកប្រចាំសហគមន៍ និងសំនួរស្ទង់មតិ ពីក្រុមមនុស្សដែលត្រូវបានផ្តាតជាសំខាន់ និងពីកិច្ចសម្ភាសន៍ផ្តល់ព័ត៌មានទូទាំងរដ្ឋកាលី ហ្វរញ៉ា។ ទិន្ននន័យរបស់ពួកយើងបង្ហាញថា **សេវាកម្មថែទាំសុខភាពផ្លូវចិត្ត គឺមិនមានលក្ខណៈសមរម្យ ឬមិនត្រូវបានផ្តល់ដល់ប្រជាជនអាស៊ីអាគ្នេយ៍(SEAAs)គ្រប់គ្រាន់នោះទេ។ ហើយជារឿយៗ សេវាកម្មនេះ បរាជ័យក្នុងការផ្តល់ជូនដល់សហគមន៍ដែលកើតមានបញ្ហា និងការប៉ះទង្គិចផ្លូវចិត្តក្នុងអត្រាខ្ពស់ដែលអ្នកទាំងនោះបានជួបប្រទះដោយមូលហេតុដូចជា សង្គ្រាម អំពើប្រល័យពូជសាសន៍ និងការផ្លាស់ទីលំនៅជាដើម។**

ប្រធានបទ

1. សេវាកម្មសុខភាពផ្លូវចិត្តដែលសមស្របតាមបែបវប្បធម៌និងភាសាត្រូវតែគិតគូដល់គ្រប់ផ្នែកដែលរួម មានវប្បធម៌ ភាពស៊ីចង្វាក់គ្នា អន្តរជំនាន់ ការព្យាបាល និងភាសា។
2. ការទទួលបានការថែទាំដែលមានលក្ខណៈសមស្របមានមុខងារសំខាន់ណាស់ក្នុងការព្យាបាល និងបញ្ចប់វដ្តនៃការប៉ះទង្គិចផ្លូវចិត្តដែលអាចប៉ះពាល់ដល់កូនចៅជនជាតិអាស៊ីអាគ្នេយ៍ជំនាន់ថ្មី។
3. ដំណោះស្រាយសហគមន៍ដ៏មានប្រសិទ្ធភាពដែលលើកឡើងនូវឧបសគ្គដែលរាំងក្នុងការទទួលបាន
   ការថែទាំ ប៉ុន្តែដំណោះស្រាយនេះមិនត្រូវបានអនុវត្តឬមិនបានធ្វើឡើងអោយបានទូលំទូលាយនោះទេ។

តើអ្នកដឹងទេ?

ជនជាតិអាស៊ីអាគ្នេយ៍កំពុងជួបវិបត្តិសុខភាពផ្លូវចិត្តក្នុងអត្រាមួយខ្ពស់ រួមមានជម្ងឺផ្លូវចិត្ត ជម្ងឺហក់ស្ទុះ និងវិបត្តិថប់បារម្ភផ្សេងៗ បើប្រៀបធៀបនឹងក្រុមប្រជាជនទូទៅ ដោយសារតែការជួបប្រទះនូវសង្គ្រាម អំពើប្រល័យពូជសាសន៍ ការផ្លាស់ទីលំនៅជាដើម។

75% នៃអ្នកឆ្លើយតបដែលត្រូវបានប៉ះពាល់ផ្ទាល់បង្ហាញថាពួកគេមិនមានលទ្ធភាពទទួលបានសេវាកម្មសុខភាពផ្លូវចិត្តដែលមានលក្ខណៈសមស្របនោះទេ។

ត្រឹមតែ 70 នាក់នៃអ្នកផ្តល់សេវាកម្មសុខភាពផ្លូវចិត្តដល់ប្រជាជនអាស៊ីប៉ាស៊ីហ្វិកដែលរស់នៅលើទឹកដីអាមេរិចគឺអាចផ្តល់សេវាកម្មសម្រាប់រាល់ប្រជាជនអាស៊ីប៉ាស៊ីហ្វិក 100,000 នាក់ ជាមួយនឹងផលធៀបទាបបំផុតក្នុងចំណោមអ្នកជំនាញថែទាំសុខភាពដែលនិយាយភាសាដើម សម្រាប់ជនជាតិឡាវ ជនជាតិកម្ពុជា និងជនអាមេរិចកាត់មង។

ដំណោះស្រាយសហគមន៍មានដូចជា៖

សេវាកម្មថែទាំព្យាបាលតាមបែបវប្បធម៌

មានន័យថា៖ វិធីសាស្ត្រដោយយោងទៅតាម គំនិតរបស់សហគមន៍ដែលជម្រុញអោយ មានការយល់ឃើញ រួមមួយទាក់ទងនឹងការព្យាបាល និងផ្តោតសំខាន់លើវប្បធម៌ ដែលជាគន្លឹះនាំទៅរកសុខុមាលភាព។

មូលហេតុដែលដំណើរការ៖ វិធីសាស្ត្រដោយយោងទៅតាមមតិយោបល់សហគមន៍ផ្តោតទៅលើវប្បធម៌វិញ្ញាណ សកម្មភាពប្រជាពលរដ្ឋ និងការព្យាបាលប្រចាំ សហគមន៍ ដើម្បីដោះស្រាយការប៉ះទង្គិចផ្លូវចិត្តជាក្រុម និងប្រវត្តិជូរចត់ដែលបានឆ្លងកាត់។

ភ្នាក់ងារគួរជាទីទុកចិត្ត និងសេវាកម្មសុខភាពប្រចាំសហគមន៍

មានន័យថា៖ សេវាកម្មសុខភាពផ្លូវចិត្តប្រចាំសហគមន៍ដែលមានទីតាំងរួមគ្នាដែលរួមបញ្ចូល ការផ្សព្វផ្សាយព័ត៌មាននិងផ្តល់ការអប់រំដល់សហគមន៍ និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត។

មូលហេតុដែលវាដំណើរការ៖ សេវាកម្មយោងទៅតាមការរៀបចំរបស់សហគមន៍ជួយ បញ្ចៀសពីភាពម៉ាក់ងាយដោយសារភាពខុសគ្នានៃវប្បធម៌ បង្កើតអោយមានការទុកចិត្តគ្នា ជាមួយអ្នកផ្តល់សេវាកម្ម និងបង្កើនការយល់ដឹងទាក់ទងនឹងផលវិបាកនៃសុខភាពផ្លូវចិត្ត និងការថែទាំនិងប្រព័ន្ធដែលកំពុងមាន។

សិទ្ធិក្នុងការទទួលបានសេវាកម្មបកប្រែភាសា

មានន័យថា៖ តម្រូវការនៃសេវាកម្មសុខភាពផ្លូវចិត្តដែលសមស្របទៅតាមវប្បធម៌និងភាសា ដែលបញ្ជាក់ពីសិទ្ធិចំបងរបស់ប្រជាពលរដ្ឋក្នុងការយល់ដឹង សម្តែងមតិ និងការសរសេរ។

មូលហេតុដែលវាដំណើរការ៖ ការដោះស្រាយនូវបញ្ហាមិនចេះភាសាសម្រាប់សហគមន៍មួយក្នុង ចំណោមសហគមន៍ធំជាងគេដែលមិនសូវចេះភាសាអង់គ្លេសនៅក្នុងរដ្ឋកាលីហ្វញ៉ាបានបង្កើតអោយមានការជឿទុកចិត្ត ស្របពេលមានការកាត់បន្ថយនូវការរើសអើង ការរំលោភបំពាន ការដាក់សម្ពាធដើម្បីសម្របខ្លួន និងការដកសិទ្ធអំណាចកុមារដែលត្រូវបានបង្ខំដើម្បីផ្សះផ្សា វប្បធម៌នៅក្នុងសង្គម។ វាក៏បានបង្កើតទំនុកចិត្តក្នុងការចែករំលែកព័ត៌មាន ពិភាក្សាអំពីប្រធានបទសំខាន់ និងការប្រើប្រាស់សេវាកម្ម មិនថាតាមរយៈអ្នកផ្តល់សេវាកម្មសុខភាពដែលនិយាយភាសាដើមកំណើត ឯកសារបកប្រែ ឬតាមអ្នកបកប្រែប្រកបដោយវិជ្ជាជីវៈក៏ដោយ។

សម្លេងសហគមន៍

សមាជិកសហគមន៍ខ្មែរបាននិយាយថា "ខ្ញុំបានក្លាយជាអ្នកបកប្រែភាសាសម្រាប់ឪពុករបស់ខ្ញុំ និងវេជ្ជបណ្ឌិតផ្នែកជម្ងឺចិត្តសាស្ត្ររបស់គាត់។ ពួកគេមិនមានអ្នកបកប្រែភាសា ហេតុនេះហើយឪពុករបស់ខ្ញុំបានយកខ្ញុំទៅជាមួយ។ លើកទីមួយហើយដែលឪពុករបស់ខ្ញុំបានពណ៌នា អំពីបទពិសោធន៍របស់គាត់កំឡុងពេលសម័យខ្មែរក្រហម។ គាត់ពិពណ៌នាយ៉ាងលំអិត និងបានទ្រហោយំ។ ខ្ញុំមិនដែលឃើញឪពុករបស់ខ្ញុំដូចនេះទេ។ ក្នុងនាមជាកូនរបស់គាត់ ខ្ញុំមានអារម្មណ៍ថាខុសឆ្គងប្រៀបដូចជាបានបំពានពត៌មានឯកជនរបស់គាត់។ ហេតុអ្វីបានជាវាមិនអីទេក្នុងការអោយកូនបកប្រែនៅក្នុងកាលៈទេសៈនោះ? ថ្វីត្បិតតែខ្ញុំមិនយល់ច្បាស់ ទាំងអស់ ក៏ខ្ញុំដឹងថាវាមិនត្រឹមត្រូវទេ។"

គម្រោងការងារនេះត្រូវបានឧបត្ថម្ភដោយអង្គការផ្តល់អំណោយប្រចាំរដ្ឋកាលីហ្វ័រញ៉ា។ សម្រាប់តារាងពេញលេញនៃឯកសារយោងនិងសេចក្តីថ្លែងអំណរគុណ សូមចូលទៅកាន់សេចក្តីរាយការណ៍ ពេញលេញតាមរយៈ **bit.ly/SEARACRight2Heal2021**